# ស្ថានទូតអូស្ត្រាលី

## ភ្នំពេញ


# សេចក្តីប្រកាសពត៌មាន

## ប្រទេសអូស្ត្រាលីគាំទ្រដល់និស្សិតខ្មែរកម្ពុជា

និស្សិតកម្ពុជាចំនួន១៦នាក់ ដែលបានទទួលអាហារូបករណ៏អូស្ត្រាលីសំរាប់ការអភិវឌ្ឍន៏ នឹងត្រូវទទួលបានការស្វាគមន៏ការត្រឡប់មកវិញ នៅក្នុងពិធីមួយដែលរៀបចំឡើងដោយលោកជំទាវឯកអគ្គរាជទូតអូស្ត្រាលីនៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០១០ ។ បន្ទាប់ពីបានបំពេញការសិក្សាអស់រយៈពេល១-២ឆ្នាំនៅប្រទេសអូស្ត្រាលីរួចមក និស្សិតអាហារូបករណ៏ទាំងអស់បានទទួលជោគជ័យក្នុងការបញ្ចប់ការសិក្សារបស់ខ្លួនពីសកលវិទ្យាល័យអូស្ត្រាលីដោយទទួលបានសញ្ញាបត្រ័ថ្នាក់អនុបណ្ឌិតក្នុងមុខជំនាញ ពាណិជ្ជកម្ម សេដ្ឋកិច្ច ការអប់រំ សុខាភិបាល ការអភិវឌ្ឍន៏អន្តរជាតិ ការគ្រប់គ្រង រដ្ឋបាលសាធារណៈ និងគោលនយោបាយសាធារណៈ ។

លោកជំទាវ **ម៉ាហ្គារ៉េត អាដាមសុន** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា បានមានប្រសាសន៏ថា "ក្រុមយុវវ័យសម័យថ្មីដែលប្រកបដោយទេពកោសល្យ និងភាពរស់រវើកទាំងនេះ តំណាងអោយការវិនិយោគដ៏ធំធេងក្នុងវិស័យធនធានមនុស្ស ។ ជំនាញ និង បទពិសោធន៏ដែលពួកគេបាននាំត្រលប់មកវិញ នឹងក្លាយជាសម្បត្តិដ៏មានតំលៃសំរាប់វិស័យឯកជន និង សាធារណៈនៅប្រទេសកម្ពុជា" ។

លោកជំទាវបានបន្ថែមទៀតថា"ប្រទេសអូស្ត្រាលីបានផ្តល់អាហារូបករណ៏ដល់កម្ពុជាអស់រយពេលជាច្រើនឆ្នាំមកហើយគឺគិតចាប់តាំងពីជំនាន់ផែនការកូឡុមបូ(Colombo Plan)នៅក្នុងទសវត្សឆ្នាំ១៩៥០មកម្លេះ ។ នេះបង្ហាញអោយឃើញពីគុណតំលៃដែលយើងខិតខំក្នុងការកសាងទំនាក់ទំនងដ៏យូរអង្វែងជាមួយប្រទេសជិតខាងនៅក្នុងតំបន់របស់យើង" ។

ជារៀងរាល់ឆ្នាំ កម្មវិធីអាហារូបករណ៏របស់អូស្ត្រាលីមានរហូតដល់ចំនួន១០០០ ដែលត្រូវបានផ្តល់ដល់ប្រទេសចំនួន៣១ ដើម្បីដោះស្រាយតំរូវការអាទិភាពអភិវឌ្ឍន៏ធនធានមនុស្សរបស់ប្រទេសជាដៃគូររបស់យើង ។ ចាប់ពីឆ្នាំ២០០៦មក ចំនួននៃអាហារូបករណ៏នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិចដែលផ្តល់ដោយ


No 16B, National Assembly Street, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh City, Kingdom of Cambodia
Telephone: 855 23 213470 Facsimile: 855 23 213413

រដ្ឋាភិបាលអូស្ត្រាលីបានកើនឡើងទ្វេរដង រហូតដល់ចំនួន ១៩,០០០ ដែលគិតជាទឹកប្រាក់ចំនួន ១.៤ ពាន់លានដុល្លាអូស្ត្រាលីក្នុងរយៈពេលប្រាំឆ្នាំ ។

អូស្ត្រាលីផ្តល់អាហាររូបករណ៍ថ្នាក់អនុបណ្ឌិតរហូតដល់ ចំនួន២៥នាក់ ក្នុងមួយឆ្នាំៗ ដល់ប្រទេសកម្ពុជា ។ ពលរដ្ឋកម្ពុជាដែលមានសក្តានុពលក្នុងភាពជាអ្នកដឹកនាំ ក៏អាចទទួលបាននូវអាហារូបករណ៍អូស្ត្រាលី នៃកម្មវិធីអាហារូបករណ៍ភាពជាអ្នកដឹកនាំផងដែរ ដោយមានការប្រកួតប្រជែងថ្នាក់តំបន់ដើម្បីទទួលបានការសិក្សាថ្នាក់បណ្ឌិតនិងអនុបណ្ឌិត និង ការបង្កើតបណ្តាញវិជ្ជាជីវៈថ្នាក់ជាតិ តំបន់ និងពិភពលោក ដែលក្នុងនោះ អាហាររូបករណ៍ចំនួន១៩ ត្រូវបានផ្តល់រួចមកហើយ ចាប់ពីឆ្នាំ២០០៧ មក ។ លើសពីនេះ កម្មវិធីអាហាររូបករណ៍ភាពជាអ្នកដឹកនាំរបស់អូស្ត្រាលី ត្រូវបានផ្តល់ដល់និស្សិតកម្ពុជារហូតដល់ចំនួន៤០នាក់ក្នុងមួយឆ្នាំៗ សំរាប់សិក្សាជំនាញវិជ្ជាជីវៈវគ្គខ្លីៗ នៅប្រទេសអូស្ត្រាលី ។

ចាប់តាំងពីកម្មវិធីអាហារូបករណ៍អូស្ត្រាលីសំរាប់ការអភិវឌ្ឍន៏ ត្រូវបានបង្កើតនៅឆ្នាំ១៩៩៤ មក មាននិស្សិតកម្ពុជាចំនួនប្រមាណ៣០០នាក់រួចមកហើយ ដែលបានទទួលអាហារូបករណ៍ ហើយទទួលបានសញ្ញាប័ត្រថ្នាក់ឧត្តមសិក្សា ពីសកលវិទ្យាល័យនិងវិទ្យាស្ថានបច្ចេកទេសនានារបស់អូស្ត្រាលី ។ ពួកគេបានត្រឡប់មកកម្ពុជាវិញ ហើយបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៏សេដ្ឋកិច្ចនិងសង្គមរបស់កម្ពុជា ហើយក្នុងនោះ មានមួយចំនួនធំបានកាន់តួនាទីជាមន្ត្រីជាន់ខ្ពស់នៅក្នុងជួររដ្ឋាភិបាល និង វិស័យឯកជនផងដែរ ។

សំរាប់ពត៌មានបន្ថែមស្តីពីអាហាររូបករណ៍អូស្ត្រាលី សូមចូលទៅកាន់វិបសាយ: www.ausaid.gov.au/scholar/default.cfm or www.australianscholarships.gov.au

**ទំនាក់ទំនងសារពត៌មាន:**

*លោក* ***ឡាកឡិន ប៉ុនធីហ្វិច (Mr Lachlan Pontifex),***

***Tel: 023 213 470***

**ស្ថានទូតអូស្ត្រាលី រាជធានីភ្នំពេញ**

ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១០